# សេចក្តីថ្លែងការណ៍រួម

## សម្ព័ន្ធសហជីព សហព័ន្ធសហជីព និងអង្គការសង្គមស៊ីវិល បង្ហាញគោលជំហររួមគ្នា ស្នើការតម្លើងប្រាក់ឈ្នួលអប្បបរមាយ៉ាងតិចចំនួន ២៣២ ដុល្លារអាមេរិក សម្រាប់ឆ្នាំ២០២៦

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៥

យើងខ្ញុំជាសម្ព័ន្ធសហជីព សហព័ន្ធសហជីព និងអង្គការសង្គមស៊ីវិល ដែលមានរាយនាមខាងក្រោម សូមបង្ហាញគោលជំហររួមគ្នាស្នើការតម្លើងប្រាក់ឈ្នួលអប្បបរមាយ៉ាងតិចចំនួន **២៣២ ដុល្លារអាមេរិក** ក្នុងមួយខែសម្រាប់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរសម្រាប់ឆ្នាំ២០២៦។ សំណើរួមលើការតម្លើងប្រាក់ឈ្នួលអប្បបរមាចំនួន **២៣២ ដុល្លារអាមេរិក** នេះ គឺផ្អែកលើស្ថានភាពចាំបាច់ទាក់ទងនឹងការចំណាយជាក់ស្តែងរបស់កម្មករនិយោជិត និងសមត្ថភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

កម្រិតប្រាក់ឈ្នួលនាពេលបច្ចុប្បន្នចំនួន ២០៨ ដុល្លារអាមេរិក ក្នុងមួយខែ មានកម្រិតទាបពុំគ្រប់គ្រាន់នឹងការចំណាយក្នុងជីវភាពរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរឡើយ។ យោងតាមរបកគំហើញនៃការស្រាវជ្រាវរបស់សម្ព័ន្ធប្រាក់ឈ្នួលអាស៊ីចេញផ្សាយក្នុងឆ្នាំ ២០២៤ លើកឡើងថា កម្មករនិយោជិតចំណាយប្រចាំខែជាមធ្យមចំនួន ៤០៨ ដុល្លារអាមេរិកលើអាហារ និងក្រៅពីអាហារ ដែលស្មើរតែទ្វេដងនៃប្រាក់ចំណូលជាមធ្យមរបស់កម្មករដែលមានត្រឹមតែចំនួន ២៥០ ដុល្លារអាមេរិក។ បន្ថែមលើនេះ វិទ្យាស្ថានស្រាវជ្រាវ Anker បានធ្វើការប៉ាន់ប្រមាណក្នុងឆ្នាំ ២០២៤ ថា កម្មករនិយោជិតម្នាក់ដែលរស់នៅក្នុងគ្រួសារនៅតំបន់នានានៃប្រទេសកម្ពុជា ត្រូវទទួលបានប្រាក់ចំណូលចំនួន ២៣២ ដុល្លារអាមេរិក ចំណែកកម្មករនិយោជិតក្នុងគ្រួសាររស់នៅទីប្រជុំជន ត្រូវទទួលបានប្រាក់ចំណូលចំនួន ៤១៧ ដុល្លារអាមេរិក ក្នុងមួយខែ ទើបគ្រប់គ្រាន់សម្រាប់ការចំណាយលើការរស់នៅក្នុងជីវភាពសមរម្យ និងលើតម្រូវការសំខាន់ផ្សេងៗទៀត ក្នុងនោះរួមទាំងរបបសន្តិសុខសង្គម។ ប្រព័ន្ធត្រួតពិនិត្យការងារយុត្តិធម៌ ឆ្នាំ ២០២៤ របស់អង្គការ CNV International បានរកឃើញគម្លាត ៤១% រវាងប្រាក់ចំណូលមធ្យម និងការចំណាយលើការរស់នៅ ដែលបង្ខំឱ្យកម្មករនិយោជិតប្រមាណ៧៣% ខ្ចីបំណុលដើម្បីផ្គត់ផ្គង់ជីវភាពដ៏លំបាកនេះ។

គម្លាតរវាងប្រាក់ឈ្នួល និងការចំណាយនេះបន្តរុញច្រានកម្មករនិយោជិតឱ្យកាន់តែធ្លាក់ក្នុងបំណុល និងភាពក្រីក្រ និងបង្ខំឱ្យពួកគេកាត់បន្ថយការចំណាយលើថ្លៃអាហារ ការថែទាំសុខភាព និងការអប់រំ។ ជារឿងពុំសមទំនងឡើយនៅពេលកម្មករនិយោជិតដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ពុំទទួលបាននូវស្ថានភាពរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ ក្នុងពេលដែលវិស័យនេះបន្តទាក់ទាញការវិនិយោគអន្តរជាតិ និងផ្តល់ប្រាក់ចំណេញច្រើនដល់ក្រុមហ៊ុនម៉ាកយីហោ និងនិយោជក។

ទោះបីជាការស្រាវជ្រាវនានាបង្ហាញថាការចំណាយជាមធ្យមរបស់គ្រួសារលើសពីកម្រិតប្រាក់ចំណូលរបស់កម្មករនិយោជិតក្តី តែក៏សហជីព និងអង្គការសង្គមស៊ីវិលយល់ស្របរួមគ្នាស្នើការតម្លើងប្រាក់ឈ្នួលអប្បបរមាចំនួនតែ ២៣២

ដុល្លារអាមេរិកសម្រាប់ឆ្នាំ២០២៦ ដែលមានកម្រិតទាបខ្លាំងជាងការចំណាយជាក់ស្តែងក្នុងជីវភាពរស់នៅរបស់កម្មករនិយោជិត ដែលចាំបាច់ត្រូវតែតម្លើងប្រាក់ឈ្នួលសម្រាប់ឆ្នាំ២០២៦។

អាស្រ័យហេតុនេះ យើងខ្ញុំជាសម្ព័ន្ធសហជីព សហព័ន្ធសហជីព និងអង្គការសង្គមស៊ីវិល ដូចមានរាយនាមខាងក្រោម ស្នើក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជរដ្ឋាភិបាលកម្ពុជា និងសមាគមនិយោជក ទទួលយកសំណើរបស់យើងខ្ញុំក្នុងការតម្លើងប្រាក់ឈ្នួលអប្បបរមាយ៉ាងតិចចំនួន **២៣២ ដុល្លារអាមេរិក** ក្នុងមួយខែ ជូនដល់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរ សម្រាប់ឆ្នាំ២០២៦៕

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
**លោក ស្រី យ៉ាង សុភ័ណ្ឌ ប្រធានសហព័ន្ធសហជីពកម្ពុជា**
**ទូរស័ព្ទ៖ 015 787 857**
**លោកស្រី ទូច សើ ប្រធានសហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**
**ទូរស័ព្ទ៖ 012 971 533**

**សម្ព័ន្ធសហជីព សហព័ន្ធសហជីព និងអង្គការសង្គមស៊ីវិល ដែលគាំទ្រសេចក្តីថ្លែងការណ៍នេះ រួមមាន៖**

១. មជ្ឈមណ្ឌលធុរកិច្ច និងសិទ្ធិមនុស្ស (**BHRRC**)
២. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (**CENTRAL**)
៣. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (**LICADHO**)
៤. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (**ADHOC**)
៥. សហព័ន្ធសហជីពកម្ពុជា (**CATU**)
៦. សហព័ន្ធសហជីពកម្ពុជាឯករាជ្យ (**CITUFED**)
៧. អង្គការមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (**CLEC**)
៨. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (**CFSWF**)
៩. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (**CTWUF**)
១០. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (**COMFREL**)
១១. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (**CCHR**)
១២. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (**CID**)
១៣. សមាគមបណ្តាញយុវជនកម្ពុជា (**CYN**)
១៤. អង្គការយុទ្ធនាការសម្លៀកបំពាក់ស្អាត (**CCC**) ប្រទេសហូឡង់
១៥. អង្គការសមធម៌កម្ពុជា (**EC**)
១៦. សហព័ន្ធសហជីពឯករាជ្យ (**INTUFE**)

១៧. សហព័ន្ធសហជីពសេរីឯករាជ្យ ( **FUFI** )
១៨. សហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ( **FTUWKC** )
១៩. សហព័ន្ធសហជីពឥទ្ធិពលការងារ ( **FULI** )
២០. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ( **IDEA** )
២១. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ នៃក្រុមហ៊ុនណាហ្គាវើលដ៏ ( **LRSU** )
២២. អង្គការពលកម្មក្រោយស្លាកសម្លៀកបំពាក់ ( **LBL** ) ចក្រភពអង់គ្លេស
២៣. អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍន៍ ( **PED** )
២៤. សូលីដា ស្វីស ( **Solidar Suisse** ) ប្រទេសស្វីស
២៥. បណ្តាញសាមគ្គីភាពម៉ាគីឡា ( **MSN)** ប្រទេសកាណាដា
២៦. អង្គការសមាគមជាងត្នោត ( **STT** )